# ការបង្ហាញព័ត៌មានទាន់ពេល

ឈ្មោះក្រុមហ៊ុនចុះបញ្ជី : **កំពង់ផែស្វយ័តក្រុងព្រះសីហនុ**
លេខកូដក្រុមហ៊ុនចុះបញ្ជី : KH1000060009
កាលបរិច្ឆេទនិងពេលវេលានៃការបញ្ជូន : **ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៥ ម៉ោង១៥:៣០នាទី**

## ហេតុការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រង ( ទម្រង់ គ.១ )

| សេចក្តីសម្រេចកោះប្រជុំមហាសន្និបាតភាគហ៊ុនិក | |
|---|---|
| ១. ប្រភេទនៃការប្រជុំភាគហ៊ុនិក | ប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ |
| ២. កាលបរិច្ឆេទនិងពេលវេលាប្រជុំ | ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២៥ |
| ៣. ទីកន្លែងប្រជុំ | សណ្ឋាគារ Raffles Hotel Le Royal, រាជធានីភ្នំពេញ |
| ៤. របៀបវារៈ | • ការចុះវត្តមាន ភាគហ៊ុនិកចូលរួម<br>• ប្រកាសហេតុ និងគោរពភ្លេងជាតិ<br>• មតិស្វាគមន៍របស់ប្រធានមហាសន្និបាតភាគហ៊ុនិក<br>• មតិ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន<br>• មតិចូលរួមរបស់ភាគហ៊ុនិកជប៉ុន<br>• បទបង្ហាញស្តីពីៈ<br>ក. របាយការណ៍ លទ្ធផលការងារអាជីវកម្ម-សេវាកម្មឆ្នាំ ២០២៤ និងទិសដៅការងារឆ្នាំ ២០២៥<br>ខ. ការណែនាំអំពី នីតិវិធី សម្រាប់ការបោះឆ្នោតបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២៤, ប្រាក់លាភការក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអមកសស សម្រាប់ឆ្នាំ ២០២៥<br>គ. សំណួរ-ចម្លើយ<br>• ប្រកាសបើក និងដំណើរការបោះឆ្នោត<br>• ប្រកាសលទ្ធផល និង មតិបិទកម្មវិធី |
| ៥. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលអាចចូលរួម | ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៥ |
| ៦. កាលបរិច្ឆេទនៃសេចក្តីសម្រេច | ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៥ |
| ៧. ផ្សេងៗ | |

- ឯកសារភ្ជាប់ ៖ សេចក្តីជូនដំណឹង ស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

**ហត្ថលេខា និងឈ្មោះបុគ្គលិក**
**ទទួលបន្ទុកក្នុងការផ្តល់ព័ត៌មាន**

ពិត ប្រាកដ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខ: ០១៧ សជណ/កសស/បេ.ធម

ថ្ងៃព្រហស្បតិ៍ ១១កើតខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ខេត្តព្រះសីហនុ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៨ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** មានកិត្តិយសសូមគោរពជម្រាបជូនដំណឹងដល់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និងប្រភេទ "គ" ទាំងអស់មេត្តាជ្រាបថា ៖ អនុលោមតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាភិបាល ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥, កសស នឹងរៀបចំការប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៨ ទៅតាមកាលបរិច្ឆេទកំណត់ ដូចខាងក្រោម ៖

១. ប្រភេទនៃការប្រជុំភាគហ៊ុនិក ៖ **មហាសន្និបាតភាគហ៊ុនិកសាមញ្ញ**
២. កាលបរិច្ឆេទកំណត់ទុក (Record Date) ៖ **ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០២៥**
៣. កាលបរិច្ឆេទអិចរាយថ៍ (Ex-rights) ៖ **ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២៥**
៤. កាលបរិច្ឆេទ មហាសន្និបាតភាគហ៊ុនិក ៖ **ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២៥**
៥. ទីកន្លែងប្រារព្ធពិធី មហាសន្និបាតភាគហ៊ុនិក ៖ **សណ្ឋាគារ Raffles Hotel Le Royal, ភ្នំពេញ**
៦. របៀបវារៈ នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក មានដូចខាងក្រោម ៖

- ការចុះវត្តមាន ភាគហ៊ុនិកចូលរួម
- ប្រកាសហេតុ និងគោរពភ្លេងជាតិ
- មតិស្វាគមន៍របស់ប្រធានមហាសន្និបាតភាគហ៊ុនិក
- មតិ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- មតិចូលរួមរបស់ភាគហ៊ុនិកជប៉ុន
- បទបង្ហាញស្តីពី ៖
  ក. របាយការណ៍ លទ្ធផលការងារអាជីវកម្ម-សេវាកម្មឆ្នាំ ២០២៤ និងទិសដៅការងារឆ្នាំ ២០២៥
  ខ. ការណែនាំអំពី នីតិវិធី សម្រាប់ការបោះឆ្នោតបែងចែកភាគលាភជូនភាគហ៊ុនិក ឆ្នាំ២០២៤, ប្រាក់លាភការក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអម កសស សម្រាប់ឆ្នាំ ២០២៥
  គ. សំណួរ-ចម្លើយ
- ប្រកាសបើក និងដំណើរការបោះឆ្នោត
- ប្រកាសលទ្ធផល និង មតិបិទកម្មវិធី

**បញ្ជាក់** ៖

ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ដូចបានកំណត់ខាងលើនេះ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការ ដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនា **ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥** ។



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក **ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០២៥** នឹងទទួលបានលិខិតអញ្ជើញ តាមរយៈមធ្យោបាយអេឡិចត្រូនិកពី ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ឬអាចស្នើសុំមក កសស តាមរយៈលេខទូរស័ព្ទទំនាក់ទំនង ដូចមានភ្ជាប់មកជាមួយ **ចាប់ពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២៥ ដល់ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២៥ ។**

ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួននាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ **នៅតែមានសិទ្ធិ** ចូលរួម និងបោះឆ្នោតក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកតាមកាលកំណត់ខាងលើ ។

ភាគហ៊ុនិកដែលធ្វើការទិញមូលបត្រកម្មសិទ្ធិរបស់ខ្លួននាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៥ **មិនមានសិទ្ធិ** ចូលរួម និងបោះឆ្នោតក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកតាមកាលកំណត់ខាងលើនោះទេ ។

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈការជូនដំណឹងខាងលើ ភាគហ៊ុនិកដែលមានបំណងចូលរួម ឬ ចាត់តំណាងចូលរួម (ភ្ជាប់ជាមួយនឹងទម្រង់ "លិខិតតែងតាំងអាណត្តិគាហក:") ក្នុងកិច្ចប្រជុំមហាសន្និបាត សូមបញ្ជាក់ការចូលរួមជាមួយ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ឬ កសស យ៉ាងយូរត្រឹម **ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២៥** ទៅតាមអាសយដ្ឋាន និងព័ត៌មានទំនាក់ទំនង ដូចខាងក្រោម ៖

១. **កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)**

- អាសយដ្ឋាន: តិរវិថីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, សង្កាត់លេខ ៣, ក្រុង-ខេត្តព្រះសីហនុ
- ទូរស័ព្ទ ឬ ប្រព័ន្ធតេឡេក្រាម: (៨៥៥) ១០ ៧៨៨ ៨៨០ / ១១ ៨១៧ ៨៤៧ / ៩៥ ៦៦៨ ៨៩៧
- សារអេឡិចត្រូនិច: pasinfo@pas.gov.kh

២. **ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាសយដ្ឋាន: អគារលេខ ៦១, មហាវិថីព្រះមុនីវង្ស, សង្កាត់ស្រះចក, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ
  - **លោក ហួត សុភី**
    ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
    អ៊ីម៉ែល: huot.sophy@acledabank.com.kh
  - **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
    ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
    អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
  - **លោក កែន រិទ្ធពុទ្ធា**
    ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
    អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
  - **កញ្ញា ចាន់ ទេពកញ្ញា**
    ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
    អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន ។/.

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**

**លូ គឹមឈន់**

**ចម្លងជូន៖**
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ក្រុមប្រឹក្សាភិបាល កសស
- មន្ត្រីត្រួតពិនិត្យរដ្ឋអម កសស
  **"ដើម្បីជូនជ្រាប"**
- ផ្សារមូលបត្រកម្ពុជា និង ក្រុមហ៊ុនមូលបត្រ
  **"ដើម្បីជូនផ្សព្វផ្សាយ"**
- ឯកសារ-កាលប្បវត្តិ



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh